00164274

C22/I/13

# នៅក្នុងអង្គបុរេជំនុំជម្រះនៃ
# អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

## នៅក្នុងបញ្ហានៃការធ្វើបណ្ដឹងឧទ្ធរណ៍ដោយអៀង សារី
## ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន
## របស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧

**សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)**

## សារណារបស់អ៊ែន ហាញឌុល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## ក្នុងនាមការបញ្ចេញយោបល់ផ្ទាល់ខ្លួន
## ១៨ កុម្ភៈ ២០០៨

ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
22 / FEB / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
22 / FEB / 2008
ម៉ោង (Time/Heure): 10 : 30'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

00164275



## I. អ្នកផ្តល់សារណា

អ៊ែន ហាញខុល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ អ៊ែន ហាញខុល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អស់រយៈពេលជាង១០ឆ្នាំ និងជាសមាជិកគណមេធាវីនៅរដ្ឋកាលីហ្វញ៉ានៃសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះគឺជាយោបល់ផ្ទាល់ខ្លួន និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។

## II. សេចក្តីសង្ខេបអំណះអំណាង

សារណានេះត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលអនុញ្ញាតឲ្យមានការផ្តល់សារណាដោយអ្នកមិនមែនជាភាគីនៃរឿងក្តីដោយអនុលោមទៅតាមមាត្រា ៣៣នៃវិធានផ្ទៃក្នុង ។

ជនជាប់ចោទអៀង សារី កំពុងព្យាយាមរកការដោះលែងបណ្តោះអាសន្នឃុំខ្លួននៅក្នុងផ្ទះរបស់គាត់ដោយសំអាងទៅលើហេតុផលជាច្រើន ហើយហេតុផលមួយក្នុងចំណោមហេតុផលទាំងនោះគឺគាត់មានសុខភាពទ្រុឌទ្រោម ។ វិធាននីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញមិនបានចែងអំពីកាលៈទេសៈ ឬលក្ខ័ណ្ឌដែលជនជាប់ចោទអាចត្រូវដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយសារមូលហេតុសុខភាពនោះទេ ។ ដោយសារមូលហេតុនេះ វាជារឿងចាំបាច់ដែលត្រូវទៅរកមើលវិធាននីតិវិធីរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ ។ ដូចអង្គជំនុំជម្រះវិសាមញ្ញដែរ មិនមានសាលាជំនុំជម្រះក្តីណាមួយចែងច្បាស់លាស់អនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយសារបញ្ហាសុខភាពនោះទេ ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិទាំងនោះបានអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ននៅក្នុងកាលៈទេសៈបីយ៉ាង៖ ពេលដែលការព្យាបាលវេជ្ជសាស្ត្រមិនមាននៅក្នុងកន្លែងឃុំឃាំងនោះ ឬប្រទេសនោះ, ដោយសារបុព្វហេតុមនុស្សធម៌នៅពេលដែលលក្ខ័ណ្ឌរបស់ជនជាប់ចោទមិនអាចស្ថិតនៅក្នុងមន្ទីរឃុំឃាំងបាន, និងនៅពេលដែលជនជាប់ចោទមិនអាចចូលរួមក្នុងការជំនុំជម្រះក្តីកើត ។

នៅពេលដែលជនជាប់ចោទត្រូវដោះលែងដោយសារត្រូវការការព្យាបាលជាចាំបាច់នោះ ការដោះលែងនោះត្រូវធ្វើឡើងដោយមានកំណត់លក្ខ័ណ្ឌចំពោះសេរីភាពធ្វើដំណើរបានត្រឹមតែនៅក្នុងមន្ទីរព្យាបាល និងត្រូវត្រឡប់មកកាន់កន្លែងឃុំខ្លួនវិញភ្លាមបន្ទាប់ពីការព្យាបាលត្រូវបញ្ចប់ ។ ករណីតែមួយគត់ដែលជន

00164276



ជាប់ចោទត្រូវដោះលែងឲ្យត្រឡប់ទៅផ្ទះដោយសារមូលហេតុសុខភាព ទំនងជានៅពេលដែលជនជាប់ចោទត្រូវបានគេពិនិត្យឃើញថាមានជម្ងឺមហារីកដែលមិនអាចវះកាត់បាន និងដែលមិនអាចព្យាបាលបាន ដោយមានការបញ្ជាក់ថាជនជាប់ចោទអាចមានជីវិតរស់នៅយ៉ាងយូរពីរ ឬបីខែទៀតប៉ុណ្ណោះ ។ ប្រសិនបើលក្ខណ្ឌសុខភាពរបស់លោកអៀង មិនមែនជិតដល់ដំណាក់កាលចុងក្រោយបង្អស់នោះទេ គាត់មិនគួរត្រូវដោះលែងពីកន្លែងឃុំខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញ និងដាក់ឲ្យនៅក្រោមការឃុំខ្លួនក្នុងផ្ទះ ដោយសំអាងលើមូលហេតុសុខភាពតែមួយនោះទេ ។

## III. អំណះអំណាង

### ក. នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញមិនបានបញ្ជាក់ច្បាស់លាស់អំពីបទដ្ឋានសម្រាប់កំណត់ថាតើពេលណាដែលការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នអាចធ្វើទៅបានដោយសំអាងលើបញ្ហាសុខភាព

១. មេធាវីរបស់អៀង សារី បានជំទាស់ទៅនឹងការរកឃើញរបស់ចៅក្រមស៊ើបអង្កេតដែលបានរកឃើញថា "មកទល់ពេលនេះ មិនមានឯកសារណាមួយរបស់មេធាវីដែលធ្វើឲ្យ[ពួកគេ]ជឿជាក់ថាស្ថានភាពសុខភាពរបស់ជនជាប់ចោទមិនអាចនៅក្នុងមន្ទីរឃុំឃាំងបាននោះទេ" ។ មេធាវីបានអះអាងថា ដោសារស្ថានភាពបេះដូងរបស់លោកអៀង

> គាត់ត្រូវការជាចាំបាច់មិនត្រឹមតែការព្យាបាលជាប្រចាំ និង សមរម្យនោះទេ ថែមទាំងបរិដ្ឋានរស់នៅមួយដែលសមរម្យបំផុតសម្រាប់សុខភាពទ្រុឌទ្រោមរបស់គាត់ទៀតផង ។ បើទោះបីជាមានការព្យាបាលវេជ្ជសាស្រ្តក៏ដោយ... ស្ថានភាពរបស់កន្លែងឃុំឃាំងគឺមិនសមស្របសម្រាប់អ្នកដែលមានសុខភាពទ្រុឌទ្រោម[របស់គាត់]ទេ ។

ដោយសារហេតុផលនេះ មេធាវីស្នើសុំឲ្យដាក់ការឃុំឃាំងលោកអៀងនៅក្នុងផ្ទះ ។

២. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា "លក្ខណ្ឌសម្រាប់ការចាប់ខ្លួន និងការឃុំឃាំងខ្លួនរបស់ជនជាប់ចោទ ត្រូវគោរពទៅតាមច្បាប់ជាធរមាន" ។ ច្បាប់ជាធរមានរួមមានទាំងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

៣. វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ថា ជនជាប់ចោទនឹងត្រូវដោះលែង នៅពេលដែលលក្ខណ្ឌសម្រាប់ការឃុំឃាំងខ្លួនលែងបំពេញបានទៀត ហើយលក្ខណ្ឌដែលមានចែងទាំងអស់មិនមានទាក់ទងនឹងបញ្ហាសុខភាពទេ ។ វិធានផ្ទៃក្នុងក៏បានចែងទៀតថា តុលាការអាចបង្គាប់ឲ្យមានការត្រួតពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ ដើម្បីកំណត់ថាតើ«ជនជាប់ចោទ....មានកាយសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជំនុំជម្រះក្តី ឬក៏ដោយសារមូលហេតុផ្សេងទៀត» ។ ប៉ុន្តែវិធានផ្ទៃក្នុងមិនបានផ្តល់ការណែនាំអំពីបទដ្ឋានសមស្របសម្រាប់កំណត់ថាតើពេលណាដែលសុខភាពទ្រុឌទ្រោមនឹងអាចធ្វើឲ្យជនជាប់ចោទមិនអាចចូលរួមជំនុំជម្រះក្តីបាន ឬប្រសិនបើ ឬនៅពេលណាដែលសុខភាពទ្រុឌទ្រោមអាចយកមកសំអាងសម្រាប់អនុញ្ញាតឲ្យមានការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ននោះទេ ។

៤. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានចែងអំពីបញ្ហាសុខភាពតែនៅក្នុងដំណាក់កាលចាប់ខ្លួនដំបូងប៉ុណ្ណោះ ដោយបានចែងថា ព្រះរាជអជ្ញារអាចបញ្ជាឲ្យមានការពិនិត្យមើលសុខភាពជនដែលត្រូវចាប់ខ្លួន ដើម្បីបញ្ជាក់ថាតើស្ថានភាពសុខភាពរបស់ជនត្រូវចាប់នោះ«សមស្របសម្រាប់ការចាប់ខ្លួន»ឬទេ ។ ដូចវិធានផ្ទៃក្នុងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌនេះមិនបានចែងអំពីលក្ខណ្ឌដើម្បីកំណត់អំពី«ការដែលអាចចូលរួមសវនាការ»បាននោះទេ ។

៥. ដោយយោងទៅលើភាពខ្វះចន្លោះនៅក្នុងច្បាប់នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ វាជាការចាំបាច់ណាស់ក្នុងការស្វះស្វែងរកការណែនាំ«ក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ» ។

**ខ. សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យមានការដោះលែងក្រៅឃុំបណ្តោះអាសន្ននៅពេលដែលការព្យាបាលវេជ្ជសាស្ត្រមិនមាន, ដោយសារបុព្វហេតុមនុស្សធម៌, និងនៅពេលដែលជនជាប់ចោទមិនអាចចូលរួមក្នុងការជំនុំជម្រះក្តីកើត**

៦. ច្បាប់នីតិវិធីរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងរ៉ាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន បានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន នៅពេលដែលអង្គជំនុំជម្រះនៃសាលាដំបូងជឿជាក់ថា ជនជាប់ចោទនឹងបង្ហាញខ្លួននៅពេលជំនុំជម្រះ និងមិនបង្កជាគ្រោះថ្នាក់ដល់ជនរងគ្រោះ និងសាក្សី ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) អង្គជំនុំជម្រះនៃសាលាដំបូងត្រូវតែដោះលែងជនត្រូវចាប់ខ្លួន លុះត្រាណាតែអង្គជំនុំជម្រះ

គិតថា ការឃុំខ្លួនបណ្ដោះអាសន្ននេះគឺសំខាន់ណាស់ដើម្បីធានាវត្តមានរបស់ជននោះនៅពេលជំនុំជម្រះ ដើម្បីជៀសវាងការបន្តរគ្រោះថ្នាក់ដល់ការស៊ើបអង្កេត ឬសវនាការ ឬដើម្បីការពារកុំឲ្យមានការបន្តរបទល្មើសថ្មីទៀត ។ មិនមានលក្ខន្តិកៈច្បាប់បង្កើតសាលាជំនុំជម្រះក្ដី និងច្បាប់នីតិវិធីរបស់សាលាជំនុំជម្រះក្ដីទាំងនេះមួយណាមានចែងច្បាស់លាស់ ដោយអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្នដោយសារមូលហេតុសុខភាពនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ សាលាជំនុំជម្រះក្ដីអន្តរជាតិធ្លាប់បានអនុញ្ញាតមានការដោះលែងក្រៅឃុំបណ្ដោះអាសន្ន នៅពេលដែលជនជាប់ចោទអាចបង្ហាញថាជនជាប់ចោទត្រូវការការព្យាបាលវេជ្ជសាស្ត្រដែលមិនអាចរកបាននៅក្នុងកន្លែងឃុំខ្លួន ឬប្រទេសឃុំខ្លួន, ខ្លួនកំពុងតែប្រឈមមុខនឹងជម្ងឺដែលឈានដល់ដំណាក់កាលចុងក្រោយ និង មិនមានពេលវេលាច្រើនសម្រាប់រស់នៅ ឬមិនអាចចូលរួមក្នុងសវនាការបាន ។

៧. ដូចចៅក្រមអង្គជំនុំជម្រះវិសាមញ្ញដែរ នៅក្នុងការពិចារណាថាតើការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយសារមូលហេតុសុខភាពសមរម្យឬអត់នោះ អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងរ៉ាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន អាចបញ្ជាឲ្យមានការត្រួតពិនិត្យវេជ្ជសាស្ត្រ ផ្លូវចិត្ត ឬផ្នែកវិបត្តិស្មារតី ចំពោះជនដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតព្រហ្មទណ្ឌ ។ សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌទាំងនេះក៏ពិចារណាផងដែរទៅលើរបាយការណ៍សុខភាព និងរបាយការណ៍របស់អ្នកជំនាញដែលផ្ដល់ជូនដោយភាគីនៅក្នុងរឿងក្ដី និងសក្ខីភាពរបស់សាក្សីដែលជាអ្នកជំនាញ ។

**១. ការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្នជាទូទៅអនុញ្ញាតតែនៅពេលដែលមិនមានការព្យាបាលគ្រប់គ្រាន់**

៨. វិធានទូទៅដែលប្រើប្រាស់ដោយសាលាជំនុំជម្រះក្ដីអន្តរជាតិគឺថា "ជម្ងឺធ្ងន់ធ្ងរតែមួយមុខមិនអាចទទួលបានការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្នទេ ដរាបណាមានការព្យាបាលគ្រប់គ្រាន់ផ្ដល់ឲ្យជនជាប់ចោទដោយសាលាជំនុំជម្រះក្ដី" ។ ជាក់ស្ដែង នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ជនជាប់ចោទហ៊ីងហ្គា ន័រមេន (Hinga Norman) និងជនជាប់ចោទម្នាក់ទៀត ត្រូវបានបញ្ជូនទៅកាន់ប្រទេសសេណេហ្គាល់ "ដើម្បីទទួលបានការព្យាបាលដែលគេគិតថាជាធម្មតា ប៉ុន្តែការព្យាបាលនេះមិនអាចរកបាននៅក្នុងប្រទេសសេរ៉ាលីអូន" ។

00164279



៩. នៅក្នុងសំណុំរឿងស្តានីស៊ីក(Stanisic) នៅសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ខាងមេធាវីបានអះអាង«ថា ជនជាប់ចោទមិនអាចព្យាបាលបានទេនៅក្នុងកន្លែងឃុំខ្លួន និងថា ប្រសិនបើជនជាប់ចោទនៅតែស្ថិតនៅក្នុងមន្ទីរឃុំខ្លួន ជនជាប់ចោទអាចបាត់បង់ជីវិត ឬមិនអាចចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងសវនាការ» ។ អង្គជំនុំជម្រះនៃសាលាដំបូងបានរកឃើញថា ភស្តុតាងពិតជាបានបង្ហាញថា ជនជាប់ចោទ«មានជម្ងឺធ្ងន់គួរសម» ។ ប៉ុន្តែ ភាគីនៅក្នុងរឿងក្តីបានជំទាស់ទៅនឹងស្ថានភាពធ្ងន់ធ្ងរនៃជម្ងឺរបស់គាត់ ។ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា បញ្ហាដែលទាក់ទងនោះគឺ«ថាតើជនជាប់ចោទ[អាច]ទទួលបានការព្យាបាលគ្រប់គ្រាន់ឬទេនៅពេលឃុំខ្លួននៅក្នុង[មន្ទីរឃុំខ្លួនរបស់អង្គការសហប្រជាជាតិ]» ។ អង្គជំនុំជម្រះនៃសាលាដំបូងបានចេញសាលក្រមមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយផ្អែកសេចក្តីសម្រេចចិត្តទៅលើសក្ខីភាពរបស់សាក្សីខាងព្រះរាជអជ្ញារ និងខាងមេធាវីដែលយល់ស្របថា ការព្យាបាលអាចធ្វើឡើងបាននៅក្នុងមន្ទីរឃុំឃាំងនៅក្នុងប្រទេសហូឡង់ និងថា ស្ថានភាពរបស់ជនជាប់ចោទត្រូវបានដោះស្រាយតាមរយៈការផ្តល់ឲ្យនូវការព្យាបាលនេះ ។

១០. ដូចគ្នាដែរ នៅក្នុងសំណុំរឿងរបស់ស្រ្ទូហ្គា(Strugar) អង្គជំនុំជម្រះកំពូលនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានពិចារណាអំពីសំណើរបស់មេធាវីដែលថា ជនជាប់ចោទគួរតែត្រូវដោះលែងនៅមុនគេណោហ្វូសម្រាប់រយៈពេល៤ខែដើម្បីទទួលការព្យាបាលវះកាត់ដូរដាក់ឆ្អឹងត្រគាកសប្បនិមិត្តទាំងមូល ។ បើទោះបីជាព្រះរាជអជ្ញារមិនជំទាស់ទៅនឹងសំណើសុំដោះលែងនៅក្រៅឃុំបណ្តោះអាសន្ននេះក៏ដោយ អង្គជំនុំជម្រះនៃសាលាកំពូលបានបដិសេធន៍សំណើរបស់មេធាវីដោយសារខាងមេធាវីខកខានមិនបានបង្ហាញថា ការវះកាត់ និងការថែទាំសុខភាពបន្ទាប់ពីការវះកាត់នោះមិន«គ្រប់គ្រាន់»ទេនៅក្នុងមន្ទីរសុខភាពរបស់សាលាជំនុំជម្រះក្តីនៅក្នុងប្រទេសហូឡង់ ។

## ២. ការដោះលែងដោយផ្អែកលើមូលហេតុមនុស្សធម៌គឺសមរម្យនៅពេលដែលជនជាប់ឃុំឃាំងមានជម្ងឺដែលប៉ះពាល់ដល់អាយុជីវិតភ្លាមៗ

១១. អង្គជំនុំជម្រះនៃសាលាដំបូងរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានថ្លែងថា «ការដោះលែងអាចធ្វើទៅបាននៅពេលដែលស្ថានភាពសុខភាពរបស់ជនជាប់ចោទមិនសមរម្យទៅនឹងការឃុំឃាំងខ្លួនបែបណាមួយ» ។ ប៉ុន្តែ ជម្ងឺធ្ងន់ធ្ងរតែមួយមុខមិនអាចអនុញ្ញាតឲ្យមានការដោះលែងនោះទេ នៅពេលដែលលក្ខណ្ឌនៃជម្ងឺនោះមិនមែនដល់ដំណាក់កាលចុង

ក្រោយ ឬប៉ះពាល់ដល់អាយុជីវិតភ្លាមៗ ឬមិនអាចព្យាបាលបាននៅក្នុងកន្លែងឃុំខ្លួន ។ «ការដែលថាជនជាប់ចោទដែលមានជម្ងឺនឹងមានអារម្មណ៍ល្អ និងអាចទទួលយកការព្យាបាល នៅក្នុងប្រទេសរបស់ជនជាប់ចោទបានច្រើនជាងដោយមានថែទាំពីក្រុមគ្រួសារ មិន...អាចធ្វើឲ្យករណីរបស់ជនជាប់ចោទជាករណីពិសេស.. .»ដែលនាំទៅដល់ការដោះលែងនៅក្រៅឃុំឡើយ ។

១២. នៅក្នុងសំណុំរឿងរូតាហ្កាន់ដា(Rutaganda) ខាងមេធាវីបានអះអាងថា ជនជាប់ចោទបានកើតមានជម្ងឺយ៉ាងធ្ងន់ធ្ងរបន្ទាប់ពីការបញ្ជូនខ្លួនគាត់ទៅកាន់កន្លែងឃុំឃាំងខ្លួនរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ។ អង្គជំនុំជម្រះនៃសាលាដំបូងបានច្រានចោលសំណើរសុំឲ្យការដោះលែងនៅក្រៅឃុំដោយសារសាលាជំនុំជម្រះក្តី«មិនទទួលបានឯកសារដែលធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ស្ថានភាពជម្ងឺរបស់ជនជាប់ចោទកាន់តែធ្ងន់ធ្ងរជាងមុន ដែលតម្រូវឲ្យមានការផ្លាស់ប្តូរស្ថានភាពឃុំខ្លួនរបស់ជនជាប់ចោទទេ» ។ ដូចគ្នាដែរនៅក្នុងសំណុំរឿងប៊ីកាមុមប៉ាកា(Bicamumpaka) ខាងមេធាវីបានអះអាងថា «ដោយសារតែការឃុំឃាំងខ្លួន ស្ថានភាពសុខភាពរបស់ជនជាប់ចោទគឺងាយនឹងក្លាយទៅជាធ្ងន់ធ្ងរជាងមុន» ។ បន្ទាប់ពីការថ្លឹងថ្លែងហេតុផលដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿងរូតាហ្កាន់ដា អង្គជំនុំជម្រះនៃសាលាដំបូងបានច្រានចោលសំណើរសុំនៅក្រៅឃុំនេះ ។

១៣. ផ្ទុយទៅវិញ នៅក្នុងសំណុំរឿងប្រាដ្យានីនទិងអ្នកផ្សេងទៀត(Brdjanin et al.) នៅឯសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ជនជាប់ចោទតាលីក(Talic) បានស្នើសុំដោះលែងខ្លួនគាត់ឲ្យទៅនៅក្នុងផ្ទះក្រុមគ្រួសាររបស់គាត់នៅក្នុងទីក្រុងបាន់ចាលូកា នៅប្រទេសបូស្នៀ និងអ៊ែរហ្សេហ្គូវីន (Bosnia and Herzegovina) ដើម្បីទទួលបានការព្យាបាល ។ អ្នកជំនាញផ្នែកសុខភាព ដែលរួមមានទាំងមន្ត្រីវេជ្ជសាស្ត្រប្រចាំនៅមន្ទីរឃុំឃាំង បានរាយការណ៍ថា តាលីកមានជម្ងឺមហារីក ជម្ងឺមហារីករបស់គាត់គឺ«មិនអាចវះកាត់ និងមិនអាចព្យាបាលបានទេ» ហើយគាត់អាចរស់នៅបានយ៉ាងយូរបំផុតប៉ុន្មានខែទៀតប៉ុណ្ណោះ ហើយមិនមានការព្យាបាលវេជ្ជសាស្ត្រណាមួយដែលនឹងអាចធ្វើឲ្យស្ថានភាពជម្ងឺរបស់គាត់ធូរស្បើយនោះទេ ។ ដោយសារមូលហេតុទាំងនេះ អ្នកជំនាញផ្នែកសុខភាពបានយល់ស្របថា ស្ថានភាពរបស់គាត់គឺមិនសមរម្យសម្រាប់ការស្ថិតនៅក្នុងមន្ទីរឃុំឃាំង ឬសម្រាប់ចូលរួមសវនាការទេ ។ អង្គជំនុំជម្រះនៃសាលាដំបូងបានរកឃើញថា ដោយសារស្ថានភាពរបស់ជនជាប់ចោទមិនអាចព្យាបាលបាន និងថាជនជាប់ចោទទំនងជាមិនអាចនៅមានជីវិតរហូតដល់ចុងបញ្ចប់នៃសវនាការរបស់គាត់ អង្គជំនុំជម្រះនៃសាលាដំបូងមានកាតព្វកិច្ចធ្វើអន្តរាគមន៍មុនពេលដែលគាត់ឈាន«ទៅដល់ការស្លាប់» និងថា ការដោះលែងឲ្យនៅក្រៅឃុំដោយគ្មានលក្ខណ្ឌគឺជារឿងចាំបាច់ ។

១៤. ស្រដៀងគ្នាដែរ នៅក្នុងសំណុំរឿងឌ្យូគី(Djuki) នៅពេលដែលជនជាប់ចោទមានជម្ងឺដែលមិនអាចព្យាបាលបាន ហើយកំពុងស្ថិតនៅក្នុងដំណាក់កាលចុងក្រោយបំផុត អង្គជំនុំជម្រះនៃសាលាដំបូងបានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្នដោយផ្អែកលើមូលហេតុមនុស្សធម៌ដោយសារ«ស្ថានភាពធ្ងន់ធ្ងរបំផុតនៃលក្ខណ្ឌសុខភាព» ។

### ៣. ការដោះលែងដោយសារមិនអាចចូលរួមសវនាការគឺអាចធ្វើទៅបាននៅពេលដែលជនជាប់ចោទមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនយ៉ាងមានប្រសិទ្ធិភាពនៅក្នុងសវនាការ

១៥. នៅពេលជនជាប់ចោទមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលបានធ្វើឲ្យខូចលទ្ធភាពប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពនូវសិទ្ធិរបស់ជនជាប់ចោទនៅក្នុងសវនាការ តុលាការអាចសម្រេចថាជនជាប់ចោទមិនអាចចូលរួមសវនាការបាន និងត្រូវដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ។ «បញ្ហាគឺមិនមែនថាតើជនជាប់ចោទមានជម្ងឺផ្នែកកាយសម្បទា ឬផ្លូវចិត្តនោះទេ ប៉ុន្តែ...ថាតើជនជាប់ចោទនោះអាចអនុវត្តសិទ្ធិរបស់គាត់បានយ៉ាងមានប្រសិទ្ធិភាពនៅក្នុងសវនាការប្រឆាំងគាត់ឬទេ» ។ ទំនាក់ទំនងត្រូវតែរកឲ្យបានរវាងការវិភាគលើស្ថានភាពជម្ងឺផ្សេងៗ និង «ឥទ្ធិពលពិតប្រាកដដែលប៉ះពាល់ដល់លទ្ធភាពផ្សេងៗរបស់ជនជាប់ចោទ» ។

១៦. សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានកំណត់លទ្ធភាពផ្សេងៗនោះដោយមានបញ្ចូលៈ លទ្ធភាពក្នុងការអះអាងថាខ្លួនមានកំហុសឬអត់ យល់អំពីចរិកនៃបទចោទប្រកាន់ យល់អំពីដំណើរការរបស់សវនាការ យល់អំពីភាពពិស្តារនៃភស្តុតាង ណែនាំមេធាវី យល់អំពីផលលំបាកនៃសវនាការ និងផ្ដល់សក្ខីភាព ។ បន្ទុកគឺត្រូវធ្លាក់ទៅលើខាងមេធាវីក្នុងការបង្ហាញដោយ«យោងទៅលើស្ថានភាពប្រហែល»ថា ជនជាប់ចោទគឺមិនអាចចូលរួមក្នុងសវនាការបានទេ ។

១៧. ជាក់ស្ដែង នៅក្នុងសំណុំរឿងស្តានីហ្ស៊ីក(Stanisic) ខាងមេធាវីបានអះអាងថា «ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងជាពិសេស ជម្ងឺពោះវៀនបានធ្វើឲ្យកាយសម្បទារបស់គាត់កាន់តែយ៉ាប់យ៉ឺន ដូច្នេះ ជម្ងឺនេះបានធ្វើឲ្យខូចលទ្ធភាពរបស់គាត់ក្នុងការចូលរួមរៀបចំការពារក្ដីយ៉ាងមានអត្ថន័យនៅក្នុងសំណុំរឿងរបស់គាត់» ។ ប៉ុន្តែ អង្គជំនុំជម្រះនៃសាលាដំបូងរបស់សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានរកឃើញថា មិនមានឯកសារវេជ្ជសាស្ត្រណាមួយនៅក្នុងចំណោមឯកសារទាំងបីដែលត្រូវបានដាក់ជូនសាលាជំនុំជម្រះក្ដីដោយខាងមេធាវី បានបង្ហាញដោយយោងទៅលើស្ថានភាពប្រហែលថា ជនជាប់ចោទមិនអាចចូលរួមនៅក្នុងការការពារក្ដីរបស់

គាត់ ដូច្នេះឯកសារនេះមិនបាន«ចង្អុលបង្ហាញនូវឃើញឲ្យ«ហេតុផលគ្រប់គ្រាន់»ដែលតម្រូវឲ្យមានការស៊ើបអង្កេតអំពីលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការទេ» ។

១៨. ផ្ទុយទៅវិញ នៅក្នុងសំណុំរឿងកូវ៉ាអេវី(Kova_evi_) សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានពិចារណាថាតើការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នអាចធ្វើបានឬទេក្នុងករណីដែលជនជាប់ចោទមានបញ្ហាផ្នែកផ្លូវចិត្ត ។ ខាងមេធាវីបានស្នើសុំឲ្យមានការដោះលែងក្រៅឃុំបណ្តោះអាសន្នដើម្បីឲ្យជនជាប់ចោទអាចទទួលបានការព្យាបាលនៅក្នុងមន្ទីរពេទ្យឯកទេសផ្លូវចិត្តនៅក្នុងប្រទេសស៊ែរប៊ី និងម៉ុនតេណេហ្គ្រូ ។ របាយការណ៍ពីអ្នកជំនាញពីររូបដែលតែងតាំងដោយសាលាជំនុំជម្រះក្តី ពីអ្នកជំនាញចិត្តសាស្ត្រមួយរូបដែលតែងតាំងដោយខាងមេធាវី និងអ្នកចិត្តសាស្ត្ររបស់កន្លែងមន្ទីរឃុំឃាំង ទាំងអស់គ្នា បានបញ្ជាក់ថា ជនជាប់ចោទ«មានជម្ងឺផ្នែកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដែលបច្ចុប្បន្ននេះធ្វើឲ្យគាត់មិនអាចការពារខ្លួនថាមានកំហុសឬអត់ និងមិនអាចចូលរួមសវនាការ»បាន និងបានឲ្យយោបល់ថា ជនជាប់ចោទត្រូវទទួលបានការព្យាបាលនៅក្នុងមន្ទីរពេទ្យដែលប្រើប្រាស់ភាសាដើមកំណើតរបស់គាត់ ។ ដោយសារមូលហេតុនេះ អង្គជំនុំជម្រះបានដោះលែងជនជាប់ចោទ ។

## ខ. លក្ខ័ណ្ឌនៃការដោះលែងដោយសារមូលហេតុសុខភាពជាទូទៅតម្រូវឲ្យមានការដាក់កំហិតការធ្វើដំណើររបស់ជនជាប់ចោទត្រឹមតែក្នុងបរវេណមន្ទីរពេទ្យ

១៩. នៅពេលដែលជនជាប់ចោទត្រូវដោះលែងជាបណ្តោះអាសន្នដោយសាលាជំនុំជម្រះក្តីអន្តរជាតិដោយសារមូលហេតុសុខភាព លក្ខណ្ឌនៃការដោះលែងជាទូទៅត្រូវកំណត់ឲ្យជនជាប់ចោទត្រឹមតែនៅក្នុងមជ្ឈមណ្ឌលព្យាបាលដែលនៅទីនោះជនជាប់ចោទទទួលបានការព្យាបាល ហើយតម្រូវឲ្យពួកគេត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញបន្ទាប់ពីការព្យាបាលត្រូវបញ្ចប់ ។ ជាក់ស្តែង នៅក្នុងសំណុំរឿងរបស់ស្រ្ទូហ្គា(Strugar) ដែលជនជាប់ចោទត្រូវបានដោះលែងឲ្យទទួលការវះកាត់នៅក្នុងប្រទេសម៉ុនតេណេហ្គ្រូ ជនជាប់ចោទតម្រូវឲ្យ«ស្ថិតនៅតែក្នុងបរវេណនៃមន្ទីរព្យាបាល....និងកន្លែងថែទាំសុខភាព» និងបន្ទាប់មកត្រូវត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ។ ដូចគ្នាដែរ នៅក្នុងសំណុំរឿងកូវ៉ាអេវី(Kova_evi_) ដែលជនជាប់ចោទត្រូវបានរកឃើញថាមិនអាចចូលរួមសវនាការបានដោយសារមូលហេតុជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរ អង្គជំនុំជម្រះនៃសាលាដំបូងបានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នឲ្យទៅព្យាបាលនៅក្នុងមន្ទីរព្យាបាលជម្ងឺផ្លូវចិត្តពិសេស ដោយមានដាក់លក្ខ័ណ្ឌថា ជនជាប់ចោទមិនអាចចាកចេញពីបរវេណ

មន្ទីរពេទ្យទេ ។ ជាងនេះទៅទៀត បន្ទាប់ពីរយៈពេល៦ខែ គេតម្រូវឲ្យមានការត្រួតពិនិត្យមើលស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទម្តងទៀតដើម្បីវាយតម្លៃថាតើស្ថានភាពរបស់ជនជាប់ចោទបានផ្លាស់ប្តូរគ្រប់គ្រាន់សម្រាប់ឲ្យជនជាប់ចោទអាចត្រឡប់មកចូលក្នុងសវនាការវិញ ។ មានតែនៅក្នុងសំណុំរឿងប្រាជ្យានីន និងអ្នកផ្សេងទៀត(Brdjanin et al.) និងសំណុំរឿងឌ្យូគី(Djuki) ដែលជនជាប់ចោទត្រូវបានរកឃើញថាមានជម្ងឺមហារីកដំណាក់កាលចុងក្រោយដែលមិនអាចវះកាត់បាន និងមានជីវិតរស់នៅតែរយៈពេលប៉ុន្មានខែប៉ុណ្ណោះ ដែលការឃុំខ្លួននៅក្នុងផ្ទះត្រូវតុលាការរកឃើញថាសមរម្យ ។

## IV. សេចក្តីសន្និដ្ឋាន

២០. យុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិស្របៗគ្នាទាក់ទងទៅនឹងការដោះលែងឲ្យនៅក្រៅឃុំផ្អែកទៅលើបញ្ហាសុខភាព គឺតែនៅពេលដែលការព្យាបាលគ្រប់គ្រាន់មិនអាចរកបាន នៅពេលដែលជនជាប់ចោទត្រូវរកឃើញថាមានជម្ងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ និងមានជីវិតរស់នៅតែក្នុងរយៈពេលខ្លី ឬនៅពេលដែលជនជាប់ចោទត្រូវតុលាការរកឃើញថាមិនអាចចូលរួមសវនាការបាន ។ នៅក្នុងករណីរបស់លោកអៀង មិនមានការអះអាងណាមួយដែលថា ស្ថានភាពសុខភាពរស់គាត់បានរាំងគាត់មិនឲ្យចូលរួមបានយ៉ាងមានប្រសិទ្ធិភាពក្នុងការការពារក្តីរបស់គាត់ និងដែលធ្វើឲ្យគាត់មិនអាចចូលរួមក្នុងសវនាការបាននោះទេ ។ ប្រសិនបើគាត់ត្រូវការការព្យាបាលពិសេសដែលអង្គជំនុំជម្រះវិសាមញ្ញមិនអាចផ្តល់ជូនបាននៅក្នុងកន្លែងឃុំខ្លួន ការដោះលែងដោយកំណត់ឲ្យធ្វើដំណើរត្រឹមតែនៅក្នុងបរិវេណមន្ទីរពេទ្យសដើម្បីទទួលបានការព្យាបាល និងសម្រាប់តែក្នុងរយៈពេលព្យាបាល គឺជារឿងសមរម្យ ។ ប៉ុន្តែ ប្រសិនបើខាងមេធាវីមិនអាចបង្ហាញថា ស្ថានភាពរស់លោកអៀងគឺដល់ដំណាក់កាលចុងក្រោយ និងដែលអាចបង្កជាមរណៈភាពភ្លាមៗទេ លោកអៀងមិនគួរត្រូវដោះលែងបណ្តោះអាសន្នឃុំខ្លួននៅក្នុងផ្ទះរបស់គាត់ដោយសារមូលហេតុសុខភាពតែមួយមុខនោះទេ ។

ដោយការគោរពយ៉ាងខ្ពង់ខ្ពស់

អ៊ែន ហាញខល

ទីប្រឹក្សាច្បាប់

មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ ១១១០

ភ្នំពេញ, ប្រទេសកម្ពុជា
៨៥៥ (០)២៣ ២១១ ៨៧៥

ចុះហត្ថលេខានៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨